**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អធិដ្ឋានសម្រាប់ការត្រាសហៅនៅភ្នំពេញថ្មី**
**ថ្ងៃទី០២ វិច្ឆិកា ២០១៧**

អត្ថបទទី១៖រម ៨,១៨-២៥
ដំណឹងល្អ៖លក ១៣,១៨-២១

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងជាគ្រូអប់រំជំនឿ យើងបានជួបជុំគ្នាដើម្បីទទួលព្រះពរពីព្រះជាម្ចាស់ នៅក្នុងអត្ថបទទីមួយយើងបានស្តាប់អំពីអ្វីដែលសំខាន់បំផុតនៅក្នុងជីវិតរបស់យើង យើងបានស្តាប់អំពីគោលដៅនៃជីវិតរបស់យើង។ គោលដៅនៃជីវិតរបស់យើង គឺទទួលការសង្គ្រោះ តែការសង្គ្រោះនេះយើងមិនទាន់បានទទួលទេ យើងកំពុងទន្ទឹងរងចាំនៅក្នុងសេចក្តីសង្ឃឹម មានន័យថាធ្វើដូចម្តេចដើម្បីទទួលជីវិតអស់កាលជានិច្ច។ បងប្អូនដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកប៉ុន្មានឆ្នាំកន្លង បានឆ្លងកាត់ជំហានទីមួយ មានព្រះវិហារខ្លះគេគោះទ្វារលោកបូជាចារ្យសួរថា មានការអ្វី? យើងឆ្លើយថាខ្ញុំសុំចូលព្រះសហគមន៍ដើម្បីបានជំនឿ ដែលជំនឿនេះណែនាំឲ្យយើងបានទទួលជីវិតអស់កល្បជានិច្ច។

លោកប៉ូលបានរំលឹកយើង យើងមិនទាន់បានទទួលការសង្គ្រោះទេ តែយើងរស់នៅក្នុងសេចក្តីសង្ឃឹមជានិច្ច នេះជាសញ្ញាសម្គាល់នៃជីវិតជាគ្រីស្តបរិស័ទ ជាអគ្គសញ្ញាណនៃជីវិតរបស់គ្រីស្តបរិស័ទ គឺសេចក្តីសង្ឃឹម។ បេសកកម្មរបស់គ្រូអប់រំជំនឿ គឺមិនមែនផ្តល់ចំណេះដឹងមួយ តែធ្វើដូចម្តេចដើម្បីបន្តជំនឿពីម្នាក់ទៅម្នាក់។ យើងទទួលបេសកកម្មមួយយ៉ាងពិសេស គឺយើងមានតួនាទីដើម្បីបើកទ្វារនៃការសង្គ្រោះតាមរយៈព្រះវិញ្ញាណដ៏វិសុទ្ធដល់បងប្អូនឯទៀត។ សន្តប៉ូល គាត់មានដាវមួយនិងគម្ពីរ ដាវបង្ហាញថាដើម្បីរំលឹកព្រះបន្ទូលរបស់ព្រះជាម្ចាស់ចូលនៅក្នុងដួងចិត្តរបស់យើង។ សន្តសិលា គាត់មានសោរ ដើម្បីបើកទ្វារស្ថានបរមសុខ។ សម្រាប់យើងក៏ដូចគ្នា យើងជាអ្នកដែលបើកទ្វារនៃការសង្គ្រោះដើម្បីទុកឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងចូលនៅក្នុងបងប្អូនឯទៀតៗ ដែលមកទទួលការអប់រំជំនឿពីយើង ដើម្បីណែនាំឲ្យព្រះវិញ្ញាណដ៏វិសុទ្ធមានសកម្មភាពពេញលក្ខណៈនៅក្នុងខ្លួនបងប្អូន។

តួនាទីមួយទៀត គឺធ្វើដូចម្តេចដើម្បីណែនាំបងប្អូនដែលទទួលការអប់រំជំនឿពីយើង ជួបជាមួយព្រះយេស៊ូគ្រីស្តផ្ទាល់? ពីថ្ងៃដែលយើងបានទទួលអគ្គសញ្ញាជ្រមុជទឹក យើង

បានភ្ជាប់ជាមួយព្រះយេស៊ូ យើងធ្វើដូចម្ដេចដើម្បីឲ្យព្រះយេស៊ូទៅជាទីពឹងរបស់បងប្អូនដែលកំពុងស្ដាប់មេរៀនរបស់យើង ធ្វើដូចម្ដេចដើម្បីឲ្យគេស្គាល់ព្រះយេស៊ូ តាមរយៈព្រះបន្ទូល តាមរយៈការអធិដ្ឋាន តាមរយៈអភិបូជា និងអគ្គសញ្ញានានា។

យើងចង់ជួបជាមួយព្រះយេស៊ូ អាស្រ័យលើយើងតើយើងបានភ្ជាប់ជាមួយព្រះយេស៊ូ យើងអាចផ្ដល់សក្ខីភាពអំពីព្រះយេស៊ូ។ ព្រះយេស៊ូផ្ទាល់ ដែលជាព្រះជាម្ចាស់របស់យើង ដែលបានជ្រើសរើសយើងដើម្បីណែនាំឲ្យជំនឿទៅគ្រប់ទីកន្លែង នៅក្នុងព្រះសហគមន៍របស់យើង។

សម្រាប់យើងជាគ្រូអប់រំជំនឿ យើងធ្វើដូចម្ដេចដើម្បីណែនាំឲ្យអ្នកដែលកំពុងស្វែងយល់ អ្នកដែលកំពុងទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានស្គាល់ព្រះសហគមន៍ដែលជាក្រុមគ្រួសារមួយដែលមានបងប្អូនដែលចេះស្វាគមន៍គ្នាទៅវិញទៅមក ដែលចេះលើកលែងទោសឲ្យគ្នាទៅវិញទៅមក។ ថ្ងៃនេះយើងបាននិយាយអំពីបងប្អូនដែលឯកោ ដោយសារគ្មានទំនាក់ទំនងជាមួយព្រះជាម្ចាស់ ដោយសារគ្មានទំនាក់ទំនងជាមួយអ្នកដទៃ។ តួនាទីរបស់ព្រះសហគមន៍ គឺទទួលមនុស្សទាំងអស់នៅក្នុងក្រុមគ្រួសារមួយដ៏អស្ចារ្យ។ ថ្ងៃនេះយើងជួបជុំគ្នាជាមួយភូមិភាគទាំងបីនៅប្រទេសកម្ពុជា យើងឃើញព្រះសហគមន៍ទៅជាកន្លែងមួយដើម្បីធ្វើជាឪពុកម្ដាយសម្រាប់បងប្អូនឯទៀតៗ ដើម្បីណែនាំឲ្យបងប្អូនឯទៀតៗរកកន្លែងមួយកក់ក្ដៅ ដើម្បីរកឃើញកន្លែងមួយដែលផ្ដល់សេចក្ដីសង្ឃឹមមួយយ៉ាងពិសេស។ មនុស្សជាច្រើននៅក្នុងពិភពលោកសព្វថ្ងៃអស់សង្ឃឹម ពេលយើងអស់សង្ឃឹមយើងធ្វើដូចម្ដេចដើម្បីដើរពីមួយថ្ងៃទៅមួយថ្ងៃ។ ប៉ុន្តែព្រះសហគមន៍ ជាកន្លែងមួយដែលផ្ដល់សេចក្ដីសង្ឃឹមដល់កំពូលគឺផ្ដល់ជីវិតអស់កល្បជានិច្ច។

**ព្រះសហគមន៍អាចទៅជាកន្លែងមួយ ជាដើមឈើមួយយ៉ាងធំដែលមានម្លប់ត្រជាក់ដើម្បីទទួលស្វាគមន៍បក្សាបក្សីទាំងអស់ គ្រប់សត្វដែលចង់ជ្រក ដែលចង់សម្រាប់ ដែលចង់ទទួលសេចក្ដីស្រឡាញ់និងធម៌មេត្តាករុណា។** ព្រះសហគមន៍ជាក្រុមគ្រួសារមួយយ៉ាងធំដែលអាចទទួលស្វាគមន៍គ្រប់ពេលវេលា ជាកន្លែងមួយដែលពោរពេញដោយសេចក្ដីស្រឡាញ់។ ព្រះសហគមន៍ ជាកន្លែងសាធារណៈដើម្បីទទួលស្វាគមន៍ព្រះជាម្ចាស់។ យើងមានគ្រាប់ពូជល្អិត ក្រោយមកក្លាយជាដើមឈើមួយយ៉ាងធំ ដែលមានមែកសាខា មានផ្កា

មានផ្លែ ដែលមានគ្រប់សត្វមកជ្រកនិងទទួលផលទាំងនោះ ដើម្បីទទួលស្វាគមន៍ ដោយបង្ហាញធម៌មេត្តាករុណារបស់ព្រះជាម្ចាស់ជានិច្ច។

ថ្ងៃនេះយើងជួបជុំគ្នា ដើម្បីគិតអំពីអត្ថន័យនៃជីវិតរបស់យើងជាគ្រូអប់រំជំនឿ និងជាគ្រីស្តបរិស័ទ យើងត្រូវការទទួលស្គាល់ថាយើងមានបេសកកម្ម និងមានតួនាទីបី។ ទីមួយ ធ្វើដូចម្ដេចដើម្បីភ្ជាប់ជាមួយព្រះយេស៊ូនៅក្នុងជីវិតរបស់យើង ពិតមែនយើងជាមនុស្សដែលមានបាប សន្តបុគ្គលទាំងឡាយក៏បានប្រព្រឹត្តអំពើបាបច្រើនដែរ ប៉ុន្តែគេបានខិតខំកែប្រែអស់ពីសមត្ថភាពដើម្បីស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងអនុវត្តតាម។ ដូច្នេះយើងត្រូវរស់នៅជាមួយព្រះយេស៊ូក្នុងបរិយាកាសរបស់ព្រះជាម្ចាស់ដូចព្រះនាងម៉ារី។ ទីពីរ រស់នៅក្នុងព្រះសហគមន៍ ស្រឡាញ់ព្រះសហគមន៍ ដោយសារព្រះសហគមន៍ជាព្រះសហគមន៍ដ៏វិសុទ្ធ ប៉ុន្តែយើងជាមនុស្សដែលមិនវិសុទ្ធ តែខិតខំធ្វើឲ្យអស់ពីសមត្ថភាពរបស់យើង ដោយស្រឡាញ់ព្រះសហគមន៍ ដោយរស់នៅក្នុងព្រះសហគមន៍ ដោយណែនាំបងប្អូនដែលទទួលការអប់រំជំនឿឲ្យគេស្រឡាញ់ព្រះសហគមន៍ដែរ។ ព្រះសហគមន៍ ជាគ្រួសារយើងដែលមានកូនក្មេង ដែលមានឪពុកម្ដាយ ដែលមានលោកតាលោកយាយ ជាគ្រួសារមួយដែលចេះស្រឡាញ់គ្នា ដែលចេះលើកលែងទោសឲ្យគ្នាគ្រប់ពេលវេលា។ ទីបី យើងត្រូវទទួលការអប់រំបន្តទៀត ដូចជាតាមរយៈសិក្ខាសាលាដែលយើងមានប្រចាំឆ្នាំ កម្មវិធីដែលយើងមានតាមព្រះសហគមន៍នីមួយៗ។ នៅក្នុងជីវិតរបស់យើង យើងត្រូវតែទទួលការអប់រំថែមទៀត ដើម្បីណែនាំឲ្យបងប្អូនស្រឡាញ់ព្រះសហគមន៍ ជួបជាមួយព្រះយេស៊ូផ្ទាល់ និងរៀបចំខ្លួនដែលពោរពេញដោយសេចក្ដីសង្ឃឹមដើម្បីទទួលជីវិតអស់កល្បជានិច្ច។

សូមព្រះវិញ្ញាណដ៏វិសុទ្ធគង់នៅជាមួយយើង ដើម្បីឲ្យយើងរួមគ្នាបន្តកសាងព្រះសហគមន៍របស់យើង នៅក្នុងសេចក្ដីស្រឡាញ់ និងនៅក្នុងសេចក្ដីសង្ឃឹម។ អាម៉ែន៕